ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
លេខៈ ០០៧ ៧ ៣៨

**សេចក្តីណែនាំ**
**ស្តីពី**
**វិធានការពង្រឹងការអនុវត្តសារាចរអន្តរក្រសួង លេខ០០១សរ.មផ-បទ**

ដោយពិនិត្យឃើញថា កន្លងមក ការអនុវត្តសារាចរអន្តរក្រសួងលេខ០០១សរ.មផ-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ រវាងក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្ម និងការប្រើប្រាស់សេវាទូរគមនាគមន៍ ពុំទាន់បានល្អប្រសើរស្របតាមស្មារតីនៃសារាចរអន្តរក្រសួងនេះនៅឡើយ។

តាមការស្រាវជ្រាវ និងស៊ើបអង្កេត ឧក្រិដ្ឋកម្មមួយចំនួនដូចជា ការជួញដូរគ្រឿងញៀន ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរមនុស្ស ការគំរាមជំរិតទារប្រាក់ ជាដើម ដែលឧក្រិដ្ឋជនបានប្រើប្រាស់ប្រព័ន្ធទូរស័ព្ទចល័ត ក៏ដូចជាប្រព័ន្ធទូរគមនាគមន៍ ដទៃទៀត ធ្វើជាមធ្យោបាយ ដោយគ្មានអត្តសញ្ញាណ ឬប្រើប្រាស់អត្តសញ្ញាណអ្នកដទៃដើម្បីភ្ជាប់បណ្តាញ ហើយបានបង្កភាពស្មុគស្មាញដល់សមត្ថកិច្ចជំនាញក្នុងការបង្ការ និងបង្ក្រាបទាន់ពេលវេលា។

ដើម្បីឲ្យការអនុវត្តសារាចរអន្តរក្រសួងខាងលើ មានប្រសិទ្ធភាព និងធានាបានការរក្សាសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សង្គមកាន់តែល្អប្រសើរ អគ្គស្នងការដ្ឋាននគរបាលជាតិ សូមធ្វើការណែនាំដល់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម ៖

១- ត្រូវចុះធ្វើការណែនាំបន្ថែមដល់សាខា ទីតាំងលក់ ឬចែកចាយស៊ីមកាតទូរស័ព្ទចល័ត ត្រូវមានអត្តសញ្ញាណប័ណ្ណរបស់អ្នកទិញ ជាវ ស៊ីមកាតទូរស័ព្ទចល័តទាំងនោះ។
២- ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំ ក្នុងករណីគេឃើញថា សាខា ទីតាំង លក់ ឬចែកចាយស៊ីមកាតទូរស័ព្ទចល័តណាមួយនៅតែប្រព្រឹត្តល្មើសទៅនឹងការណែនាំ ត្រូវតែធ្វើការឃាត់អប់រំដល់អ្នកលក់ ឬចែកចាយ ព្រមទាំងដកហូតស៊ីមកាតទាំងនោះដើម្បីរក្សាទុក។
៣- ត្រូវណែនាំនគរបាលប៉ុស្តិ៍រដ្ឋបាលឲ្យជំរុញដល់អ្នកប្រើប្រាស់លេខទូរស័ព្ទកន្លងមក ដែលគ្មានអត្តសញ្ញាណប័ណ្ណ ត្រូវមកចុះឈ្មោះឡើងវិញនៅនគរបាលប៉ុស្តិ៍រដ្ឋបាលមូលដ្ឋាន។
៤- ធ្វើរបាយការណ៍ប្រចាំខែអំពីលទ្ធផល នៃការអនុវត្តសេចក្តីណែនាំនេះមកសេនាធិការដ្ឋាននៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

ទទួលបានសេចក្តីណែនាំនេះ ស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៥
អគ្គស្នងការនគរបាលជាតិ